**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

# លិខិតថ្វាយព្រះអំណរសាទរ

## សូមក្រាបបង្គំទូលថ្វាយ
## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

**ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!**

ក្នុងឱកាសដ៏មហាប្រសើរឧត្តុង្គឧត្តមប្រកបដោយមហាកិត្តិយសជាតិកម្ពុជា ដែល **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ព្រះអង្គទទួលបានការ ថ្វាយព្រះរាជគោរមងារកិត្តិយសថ្នាក់ខ្ពស់បំផុតខាងព្រះពុទ្ធសាសនាជា **ព្រះរាជពុទ្ធមាមកាភិបាល នៃអង្គការពុទ្ធសាសនិកពិភពលោក** ទូលព្រះបង្គំយើងខ្ញុំជាថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ សូមព្រះបរមរាជានុញ្ញាតក្រាបបង្គំទូលថ្វាយព្រះអំណរសាទរនិងព្រះពរថ្វាយ **ព្រះករុណាជាអម្ចាស់** ប្រកបដោយកក្តីភាព សូមព្រះអង្គសមប្រកបដោយព្រះរាជសុខភាពមាំមួនល្អបរិបូរណ៍ ព្រះបញ្ញាញាណវាងវៃ និងព្រះជន្មាយុយឺនយូរ។

ការថ្វាយព្រះរាជគោរមងារកិត្តិយសថ្នាក់ខ្ពស់បំផុតខាងព្រះពុទ្ធសាសនា ថ្វាយ **ព្រះករុណាជាអម្ចាស់** គឺជាមហាកិត្តិយសរបស់ជាតិ និងប្រជារាស្ត្រទូទាំងនគរកម្ពុជា ដែលនេះគឺជាសក្ខីភាពសបញ្ជាក់យ៉ាងប្រត្យក្សអំពីទសពិធរាជធម៌របស់ **ព្រះករុណាជាអម្ចាស់** ក្នុងព្រះរាជសកម្មភាពដ៏ឧត្តុង្គឧត្តម ប្រពៃថ្លៃថ្លាប្រកបដោយទឹកព្រះទ័យស្នេហាជាតិមាតុភូមិ សាសនា និងមនុស្សជាតិ ក្នុងបុព្វហេតុសន្តិភាព ភាតរភាព សុភមង្គល និងការអភិវឌ្ឍសង្គម។

ក្នុងឱកាសដ៏មហាប្រសើរឧត្តុង្គឧត្តមនេះ ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នាសូមលើកអញ្ជលីប្រណម្យបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ ព្រមទាំងវត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោក មានទេវតារក្សាព្រះមហាស្វេតច្ឆត្រ តេជៈបារមីនៃអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រីយានី សូមយាងប្រោះព្រំព្រះរាជសព្ទសារធុការពរ បវរសួស្តី សិរីមង្គល វិបុលសុខដ៏មហាប្រសើរថ្វាយ **ព្រះករុណាជាអម្ចាស់** សូមព្រះអង្គបរិបូរណ៍ដោយព្រះបរមសេចក្តីសុខ និងពលានុភាពខ្លាំងក្លា ដើម្បីគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់សម្រាប់កូនចៅ ចៅទួត ជាទីស្រឡាញ់របស់ព្រះអង្គជានិច្ចនិរន្តរ៍តរៀងទៅ។

សូម **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះមេត្តាទទួលនូវអភិវន្ទន៍កិច្ច និងព្រះសេយ្យកក្តីដ៏ស្មោះស្ម័គ្របំផុតពីទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា។

សេចក្តីគួរពុំគួរ សូមទ្រង់ព្រះមេត្តាប្រោស។

ថ្ងៃសៅរ៍ ៧ កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ២០២៣
**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

**ព្រំ-សុខា**

ផ្លូវវិថីអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh